**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៩៦
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៩
**សាលដីកា**
លេខ:២២៣
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .................

**តំណាងមហាអយ្យការ**

-លោក ............... ជាអគ្គព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៥៥ចុះថ្ងៃទី២៤ខែវិច្ឆិកាឆ្នាំ១៩៩៨នៃសំណុំរឿងរដ្ឋប្បវេណី លេខ ៦៤២ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ពក ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរមុខរបរ ធ្វើស្រែ ទីលំនៅភូមិស្វាយព្រៃ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ព្រំ ឡែម(ស) ម្តាយឈ្មោះគ្រួច យាម(រ) ប្រពន្ធឈ្មោះកង ភឿន ។

មានមេធាវី លោកស្រី ........ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ពល ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរមុខរបរ ធ្វើស្រែ ទីលំនៅ ភូមិគោកចំបក់ ឃុំស្វាយដង្គំ ស្រុកសៀមរាម ខេត្តសៀមរាម ។ឪពុកឈ្មោះ ស្វាយ ពិន(រ) ម្តាយឈ្មោះយី សៀម(រ) ប្រពន្ធឈ្មោះសុខ ឡុន ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ ១៦,៧មx៤៤ម

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ៧៤៥ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៩៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២០-១១-៩៦ របស់ដើមចោទប្តឹងទាមទារសិទ្ធិគ្រប់គ្រងដី១ប្លង់ ទំហំ១៦,៧ម x ៤៤ម ពីចុងចម្លើយឈ្មោះ ពក ដោយសំអាងហេតុថា ដីដែលមានទំនាស់នេះ ជារបស់ខ្លួនតាំងពីសង្គមចាស់ ដែលមានដំណាំ

ដូងស្វាយ លុះដល់ឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៤ ម្ដាយរបស់ខ្លួនមកកាន់កាប់ និងគ្រប់គ្រងថែរក្សាដំណាំចាស់ ហើយថែមទាំងបេះភោគផលដំណាំទាំងនោះ ។ ក្រោយពីម្ដាយក្មេកខ្លួនស្លាប់ទៅខ្លួនបានមកគ្រប់គ្រងជំនួស ដោយបានធ្វើពាក្យសុំកាន់កាប់ដីធ្លីក្នុងខែ០៧ ឆ្នាំ១៩៩៦ លុះខែ១១-១៩៩៦ ខ្លួនដឹកឈើទៅធ្វើផ្ទះលើដីទំនាស់ ស្រាប់តែចុងចម្លើយ ជំទាស់មិនឱ្យខ្លួនធ្វើ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃ សេចក្ដីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់ដីមួយកន្លែងស្ថិតនៅ ភូមិស្វាយព្រៃ ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលមានទំហំ៤៥៧ម$^{២}$ គឺព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង ពក ខាងកើតទល់នឹងផ្លូវរទេះ និងខាងលិចទល់នឹង ហ៊ឹម សុវណ្ណ ឱ្យឈ្មោះ ពល មានសិទ្ធិកាន់កាប់ និងប្រើប្រាស់ ។

៣- សម្រេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូករួម៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០៛ ដែលដើមចោទបានបង់ទុករួចស្រេចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវ បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧.០០០៛ ទៅដើមចោទវិញ នឹងបង់ពន្ធសមាមាត្រមួយភាគរយលើមាស១តម្លឹង បន្ថែមទៀត ដែលត្រូវដាក់ចូលថវិការដ្ឋ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីក្នុងប្រទេសកម្ពុជា២០ភាគរយ ប្រាក់នេះ ត្រូវបង្គាប់ឱ្យដើមចោទបង់មុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយបង់ជាក្រោយ ។

៤. សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយបើក ផ្លូវប្ដឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីសាលក្រមកំបាំងមុខ និងបើកផ្លូវឧទ្ធរណ៍កំណត់២ខែ គិតពីថ្ងៃសាលក្រមចូលចំពោះមុខ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៧ របស់លោក ព្រំ កាំង បានប្ដឹងមិនសុខចិត្តនឹងសាលក្រមលេខ៣២ ចុះថ្ងៃទី១៤ ខែ មីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ លើសេចក្ដីវិនិច្ឆ័យទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៤០៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦-០៥-៩៧ របសំឈ្មោះពក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី១៩.០៣.៩៧ របស់តុលាការខេត្តសៀមរាប ទុកជាបានការដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមបណ្តឹង ឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធហ៊ីង និងពន្ធចុះបញ្ជីក្តី ចំនួន២៥០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៥៥០០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ចំនួន៥.០០០៛ សរុប១៣.០០០៛ ។

៤. សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមតំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៣៥ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨ របស់ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤០៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើវិនិច្ឆ័យសេចក្តី នៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៤៥ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១៧.០៨.៩៨ របស់ឈ្មោះពក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទោស នឹងគតិច្បាប់ ។

២. តម្កល់សាលដីកាកំបាំងមុខលេខ៤០៧ ចុះថ្ងៃទី២០-៧-៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣. សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោកព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧៤៥ចុះថ្ងៃទី២៤ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើវិនិច្ឆ័យសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី១៣-០៨-១៩៩៩ របស់ឈ្មោះ ព្រំ កាំង

បានឃើញសារណាតបចុះថ្ងៃទី១៨-០៨-១៩៩៩ របស់ឈ្មោះ ពល

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា។

-សាលដីការដ្ឋប្បវេណីលេខ៧៤៥ ចុះថ្ងៃទី២៤-១១-៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ព្រំ កាំង ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា ពីឆ្នាំ១៩៧៩ មកមានឈ្មោះ ស៊ុន ឌី បានរស់លើដីនេះ ខ្លួនមានផ្ទះនៅពីក្រោយ ស៊ុន ឌី ដល់ឆ្នាំ ១៩៨២ ឈ្មោះ ស៊ីន ឌី ក៏ស្លាប់ ហើយបានប្រគល់ដីឱ្យ ឈ្មោះ ជិប ខាវ បន្តមរតក ដល់ឆ្នាំ១៩៨៦ ខ្លួនបានទិញដីនេះ ជិប ខាវ ដោយឃើញជិប ខាវ បានទទួលផលលើដីនេះកន្លងមក ។ ពេលទិញហើយ ខ្លួនក៏បានដាំដំណាំយកផលបម្រើជីវភាពប្រចាំថ្ងៃ។ ពល នៅភូមិផ្សេងទេ រដ្ឋាភិបាលបានប្រកាសថា នរណានៅភូមិណាកាន់កាប់ដីភូមិនោះវិញ ខ្លួនបានលិខិត

ទទួលស្គាល់ពីភូមិ-ឃុំ ប៉ុណ្ណោះ ក្រោយពីទិញបានបីបួនខែ ពល មកប្តឹងខ្លួន ។ មុនទិញដីនេះ ខ្លួនដឹងថា ស៊ុន ឌី ជាអ្នកកាន់កាប់រស់នៅ ក្រោយមកប្អូនថ្លៃ ស៊ីន ឌី ឈ្មោះ ជិប ខាវ បានគ្រប់គ្រងបន្តទៀត ។ ការទិញដីនេះមានលិខិតស្នាមត្រឹម ភូមិ-ឃុំ ធ្វើនៅខែមិថុនា ឆ្នាំ១៩៩៦ មុនកើតរឿង ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ពល ពេលជំនុំជំរះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោកស្រីស៊ិន សុវន បញ្ជាក់ថា : ដីនេះ ពីមុន ស៊ីន ឌី គ្រប់គ្រងដល់ឆ្នាំ១៩៨២ ឱ្យជីបខាវគ្រប់គ្រងបន្ត ដល់ឆ្នាំ១៩៩៦ ឈ្មោះពល ក្រោយពីស៊ុន ឌី ស្លាប់មិនដែលមានមុខទេ ។ ពេលខ្ញុំចុះទៅផ្ទាល់ប្រជាជនថា ដីនេះជារបស់ស៊ុន ឌី ការទិញរបស់ ព្រំ កាំង មានលិខិតស្នាមត្រឹមត្រូវ ក្រោយមក៤ខែហើយបាន ពល មក តវ៉ាកូនក្តីខ្ញុំជាជនរងគ្រោះ ការទិញដីនេះក៏ស្របច្បាប់១ ២ ៣ នៃក្រិត្យច្បាប់លេខ៣៨ ក្រ.ច ឈ្មោះ ពល មិនបានមករស់នៅលើដីទំនាស់ទេ ហើយក៏មិនបានកាន់កាប់ដែរ ពាក្យកាន់កាប់របស់ ពល ធ្វើក្រោយការទិញរបស់កូនក្តីខ្ញុំ ។

សូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និង សុំសិទ្ធិឱ្យកូនក្តីខ្ញុំបានកាន់កាប់ដីនេះជាកម្មសិទ្ធិតទៅ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោក ពក សារណារបស់លោក ពល សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី១៤-០១-៩៩ របស់លោកព្រំ កាំង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលលោក ពក លើកឡើងនៅក្នុងសារណាចុះថ្ងៃទី១៣-០៨-៩៩ របស់លោកថា ដីទំនាស់នេះ លោក ជិប ខាវ បានគ្រប់គ្រងធំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៦ ធ្វើឱ្យលោកមានសិទ្ធិលើដីទំនាស់នេះ តាមមាត្រា២ នៃអនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២.០៨.៨៩ និងតាមមាត្រា១៩,២០ និង២១ នៃច្បាប់ភូមិបាលនោះជាការពុំត្រឹមត្រូវទេ ពីព្រោះលោកពុំមាន ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លោកពិតជាបានគ្រប់គ្រងដីទំនាស់នេះទេ សូម្បីតែរូបលោក ជិប ខាវ ផ្ទាល់ក៏បានឆ្លើយនៅមុខមន្ត្រីយុត្តិធម៌ស្រុក និងរដ្ឋអំណាចភូមិឃុំ កាលពីថ្ងៃទី០៦-១១-៩៦ ថា ពេលខ្លួនលក់ដីឱ្យលោក ពក ខ្លួនដឹងថា ដីទំនាស់នេះជារបស់តាសុខ និង យាយ ហ៊ត់ ដែរ ។

-យល់ឃើញថា ការដែលលោក ពក និងមេធាវីរបស់លោក លើកឡើងថា ការទិញដីទំនាស់នេះ ពីលោកជីប ខាវ មានកិច្ចសន្យាត្រឹមត្រូវតាមមាត្រា១,២,៣,៣៤ និង៤១ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច. ចុះថ្ងៃទី២៨-១០-៨៨ ហើយ នោះជាការភ័ន្តច្រឡំ ពីព្រោះលោក ជិប ខាវ មិនមែនជាម្ចាស់ដីទេ ដូច្នេះកិច្ចសន្យាលក់ទិញនេះ ត្រូវទុកជាមោឃៈតាមមាត្រា៣៥ នៃក្រឹត្យច្បាប់ ដដែលនេះហើយ ។

-យល់ឃើញថា ដើមចោទបានផ្ញើសារណាការពាររឿងក្តីរបស់លោក ជូនមកតុលាការ កំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខ លោកប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៤៥ ចុះថ្ងៃទី២៤-១១-៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តី ចំពោះមុខលោកព្រំ កាំង កំបាំងមុខលោកពល។

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់ លោកពក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៤៥ ចុះថ្ងៃទី២៤-១១-៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣. រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ពក បានបង់រួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិមប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

បង្គាប់ឱ្យលោក ពក បង់ពន្ធសមាមាត្រ តាមការកំណត់ របស់តុលាការខេត្តសៀមរាប ។

៤. សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលាឆ្នាំ២០០០ ។